# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពណ៌នាអំពីសូចនាករសេដ្ឋកិច្ចនៅប្រទេសធំៗមួយចំនួន និងនៅអាស៊ីអាគ្នេយ៍។

នៅត្រីមាសទី១ ឆ្នាំ២០១៦ ផសស ពិត នៅឥណ្ឌូនេស៊ីកើន ៤,៩% ធៀបនឹង ៥,០% កាលពីត្រីមាសទី៤ ឆ្នាំ២០១៥។ ក្នុងត្រីមាសនេះដែរ ឥណ្ឌូនេស៊ី អាចធ្វើឲ្យអតិផរណារបស់ខ្លួនមានលំនឹង និងកែប្រែនយោបាយរូបិយវត្ថុ ដោយកាត់បន្ថយអត្រាការប្រាក់មកត្រឹម ៦,៥%។ កំណើនប្រចាំឆ្នាំនៅម៉ាឡេស៊ី ធ្លាក់ចុះមកត្រឹម ៤,២% ធៀបនឹង ៤,៥% ក្នុងត្រីមាសមុន ក្នុងនេះតម្រូវការក្នុងស្រុកដែលតំណាងឲ្យ ៨៥% នៃកំណើនសេដ្ឋកិច្ចសរុប គឺជាកត្តាជំរុញចម្បង។ សេដ្ឋកិច្ចសិង្ហបុរីកើន ១,៨% គឺប៉ុនគ្នានឹងត្រីមាសមុន។ សេដ្ឋកិច្ចថៃមានអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ៣,២% ធៀបនឹង ២,៨% ក្នុងត្រីមាសមុន រីឯវៀតណាមមានអត្រាកំណើន ៥,៥% គឺទាបជាងអត្រា ៧,០% កាលពីត្រីមាសមុនដោយសារចំណូលបានពីប្រេងឆៅនិងកសិកម្មបានរួមចុះ។

ចិនមានអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ៦,៧% ហើយឧស្សាហកម្មបានរួមចំណែកយ៉ាងសំខាន់ នៅក្នុងត្រីមាសទី១នេះ។ សេដ្ឋកិច្ចហុងកុងមានអត្រាកំណើន ០,៨% គឺទាបជាងអត្រាកំណើនរំពឹងទុកពី ១,០% ទៅ ២,០% និងទាបជាងកាលពីត្រីមាសមុន ដែលមានអត្រាកំណើន ១,៩% ដោយសារការធ្លាក់ចុះសកម្មភាពលក់ទំនិញរាយ និងការចុះថ្លៃអចលនទ្រព្យ។ នៅត្រីមាសទី១ កំណើននៅកូរ៉េខាងត្បូង មានត្រឹម ២,៧% ដែលទាបជាងការរំពឹងទុក និងទាបជាងកាលពីត្រីមាសមុន ដែលមានដល់ ៣,០% ។ កំណើន ផសស គិតក្នុងមួយឆ្នាំនៅតៃវ៉ាន់ រួមចុះ ០,៨% ដោយសារការនាំចេញមានកម្រិតទាប។ ការនាំចូលក៏រួមចុះដែរ ប៉ុន្តែចុះតិចជាងការនាំចេញ។

ក្នុងត្រីមាសទី១ កំណើន ផសស ពិតក្នុងតំបន់ អឺរ៉ូ ១២ នៅថេរ ត្រឹម ១,៥% គិតក្នុងមួយឆ្នាំ។ សេដ្ឋកិច្ចជប៉ុនមានកំណើន ០,២% ក្នុងត្រីមាសទី១ នេះ។ ចំណាយប្រើប្រាស់ក្នុងស្រុកនៅជប៉ុនកើនឡើង ប៉ុន្តែការនាំចេញជួបការលំបាក ដោយសារប្រាក់យ៉េនឡើងថ្លៃ។ អត្រាកំណើនប្រចាំឆ្នាំនៅសហរដ្ឋអាមេរិកកើនឡើង ២,១% ដោយសារការកែលំអវិនិយោគផ្នែកពាណិជ្ជកម្ម និងជំនួញ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

អត្រាអតិផរណាក្នុងប្រទេសអាស៊ី និងអាស៊ានខ្លះ បានកើនឡើង ប៉ុន្តែក្នុងប្រទេសខ្លះទៀតនៅតែមានបរិត្តផរណា។ នៅកម្ពុជា អតិផរណាមានកម្រិត ២,៤% ហើយនៅឥណ្ឌូនេស៊ីមានដល់ ៤,៣%។ នៅសិង្ហបុរី មានបរិត្តផរណា ០,៨% ធៀបនឹងបរិត្តផរណា ០,៧% ក្នុងត្រីមាសទី៤ ឆ្នាំ២០១៥។ សិង្ហបុរីមានអតិផរណាអវិជ្ជមានក្នុង ៥ត្រីមាសជាប់ៗគ្នា។ ថៃមានបរិត្តផរណា ០,៥% ធៀបនឹងបរិត្តផរណា ០,៩% កាលពីត្រីមាសមុន។ ការថយចុះភាពគ្មានការងារធ្វើ កំណើនការនាំចេញមាស ចំណូលយ៉ាងខ្ពស់ផ្នែកទេសចរណ៍ និងការថយចុះការនាំចូលទំនិញ បានរួមចំណែកដល់ការធ្លាក់ចុះបរិត្តផរណា។ អតិផរណានៅវៀតណាម មានអត្រា ១,៣% ដោយសារថ្លៃប្រេងក្នុងពិភពលោកកើនឡើង និងការផ្គត់ផ្គង់អាហារក្នុងទីផ្សារធ្លាក់ចុះ។

អតិផរណានៅចិន មានអត្រា ២,១% គឺខ្ពស់ជាងកាលពីត្រីមាសមុន។ ថ្លៃអាហាររួមចំណែក ២៥% ក្នុង កំណើន CPI នៅចិន។ ហុងកុងមានអត្រាអតិផរណា ២,៩% កូរ៉េខាងត្បូងមានអត្រា ០,២% តៃវ៉ាន់មានអត្រា ១,៧% តំបន់អឺរ៉ូមានអត្រា ០,១% ជប៉ុនមានអត្រា ០,២% និងសហរដ្ឋអាមេរិក មានអត្រា ១,១%។

នៅត្រីមាសទី១ ឆ្នាំ២០១៦ ទល់នឹងប្រាក់ដុល្លារ ប្រាក់រៀលធ្លាក់ថ្លៃ ០,៨% ធៀបនឹងត្រីមាសមុន និង ០.៣% ធៀបនឹងឆ្នាំមុន មកត្រឹម ៤០៥៦,៣រៀល/ដុល្លារ។ ប្រាក់បាតថៃឡើងថ្លៃ ១,១% ធៀបនឹងត្រីមាសមុន ប្រាក់ដុងវៀតណាមឡើងថ្លៃ ២,៧% ប្រាក់យ៉ន់ចិន ឡើងថ្លៃ ០,១៦% ហើយ ប្រាក់យ៉េនជប៉ុនឡើងថ្លៃ ៦,៤%។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

ក្នុងត្រីមាសទី១ ឆ្នាំ២០១៦ ថ្លៃទំនិញសំខាន់ៗនៅលើទីផ្សារពិភពលោក បានធ្លាក់ចុះ ធៀបនឹងត្រីមាសមុន។ ពោតធ្លាក់ថ្លៃ ៨,២% មកត្រឹម ១៦០,០ដុល្លារ/តោន ប្រេងដូងប្រេងធ្លាក់ថ្លៃ ៦,៥% មកត្រឹម ៥៨៦,៩ដុល្លារ/តោន ហើយ កៅស៊ូធ្លាក់ថ្លៃ ១៧,៩% មកត្រឹម ១១៩០,០ដុល្លារ/តោន។ អង្ករធ្លាក់ថ្លៃ ៩,៥% មកត្រឹម ៣៨៥,៣ដុល្លារ/តោន ហើយ សណ្ដែកសៀងធ្លាក់ថ្លៃ ២៤,១% មកត្រឹម ៣២៨,០ដុល្លារ/តោន។ ប្រេងឆៅ ធ្លាក់ថ្លៃ ៣៨,៧% មកត្រឹម ៣១,២ដុល្លារ/ធុង បណ្ដាលឲ្យ សាំងធ្លាក់ថ្លៃ ៣០,៣% និង ម៉ាសូតធ្លាក់ថ្លៃ ៣៩,១%។

អត្ថបទនេះ រៀបរាងដោយលោកស្រី ស្រ៊ី បុប្ផារ័ត្ន ជាអ្នកស្រាវជ្រាវ និង លោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៦ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 6.7 | 0.1 | 6.0 | 7.1 | 7.3 | 7.4 | | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 6.1 | 4.2 | 6.2 | 6.5 | 6.3 | 5.8 | 5.2 | 4.7 | 4.7 | 4.7 | 5.0 | 4.9 |
| ម៉ាឡេស៊ី | 4.6 | -2.4 | 9.0 | 4.9 | 5.4 | 4.6 | 6.0 | 5.6 | 4.9 | 4.7 | 4.5 | 4.2 |
| សិង្ហបុរី | 1.1 | -4.5 | 14.7 | 4.7 | 1.3 | 3.8 | 3.0 | 2.6 | 1.8 | 1.9 | 1.8 | 1.8 |
| ថៃ | 2.6 | 3.3 | 7.9 | 0.0 | 6.7 | 2.8 | 1.6 | 3.3 | 2.2 | 2.9 | 2.8 | 3.2 |
| វៀតណាម | 5.7 | 5.4 | 6.4 | 6.2 | 5.2 | 5.4 | 5.9 | 6.1 | 6.5 | 6.8 | 7.0 | 5.5 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 9.0 | 8.2 | 10.4 | 9.3 | 7.7 | 7.7 | 7.3 | 7.1 | 7.0 | 6.9 | 6.8 | 6.7 |
| ហុងកុង | 2.4 | -3.2 | 6.9 | 4.9 | 2.9 | 3.0 | 2.3 | 2.1 | 2.8 | 2.3 | 1.9 | 0.8 |
| កូរ៉េខាងត្បូង | 2.2 | -1.0 | 6.1 | 3.6 | 2.1 | 2.8 | 3.4 | 2.4 | 2.2 | 2.7 | 3.0 | 2.7 |
| តៃវ៉ាន់ | 0.1 | -3.6 | 11.1 | 4.2 | 1.2 | 2.2 | 3.5 | 3.4 | 0.5 | -1.0 | -0.5 | -0.8 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.9 | -3.8 | 1.6 | 1.6 | -0.5 | 0.1 | 0.7 | 1.0 | 1.2 | 1.6 | 1.5 | 1.5 |
| ជប៉ុន | -0.7 | -5.4 | 4.1 | -0.8 | 1.7 | 1.7 | 0.6 | -0.9 | 0.7 | 1.0 | 0.5 | 0.2 |
| សហរដ្ឋអាមេរិក | 1.1 | -2.5 | 2.7 | 1.8 | 2.1 | 1.8 | 2.4 | 2.7 | 2.3 | 2.2 | 1.8 | 2.1 |

Sources: International Monetary Fund, Economist and countries' statistics offices

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៦ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 19.7 | | 4.1 | 5.5 | 3.0 | 3.0 | 3.9 | 1.0 | 1.0 | 0.8 | 2.0 | 2.4 |
| ឥណ្ឌូនេស៊ី | 10.1 | 4.7 | 5.1 | 5.4 | 4.3 | 7.0 | 6.4 | 6.6 | 7.1 | 7.1 | 4.8 | 4.3 |
| ម៉ាឡេស៊ី | 5.3 | 0.4 | 1.7 | 3.2 | 1.7 | 2.1 | 3.2 | 0.7 | 2.1 | 3.0 | 2.6 | 3.4 |
| សិង្ហបុរី | 6.5 | 0.5 | 2.9 | 5.2 | 4.6 | 2.3 | 1.0 | -0.3 | -0.4 | -0.6 | -0.7 | -0.8 |
| ថៃ | 5.5 | -0.9 | 3.1 | 3.8 | 3.0 | 2.2 | 1.9 | -0.5 | -1.1 | -1.1 | -0.9 | -0.5 |
| វៀតណាម | 23.3 | 7.3 | 9.0 | 18.6 | 9.3 | 6.6 | 4.8 | 0.7 | 1.0 | 0.5 | 0.3 | 1.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 5.9 | -0.8 | 3.2 | 5.4 | 2.7 | 2.6 | 2.0 | 1.2 | 1.4 | 1.7 | 1.5 | 2.1 |
| ហុងកុង | 4.3 | -0.3 | 2.4 | 5.3 | 4.1 | 4.0 | 4.4 | 4.4 | 3.1 | 2.3 | 2.4 | 2.9 |
| កូរ៉េខាងត្បូង | 4.6 | 2.8 | 3.0 | 4.4 | 2.1 | 1.1 | 1.3 | 0.6 | 0.5 | 0.6 | 1.1 | 0.2 |
| តៃវ៉ាន់ | 3.2 | -1.1 | 1.0 | 1.4 | 1.9 | 0.8 | 1.5 | 2.9 | -0.7 | 0.0 | 0.3 | 1.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 3.3 | 0.4 | 1.6 | 2.7 | 2.5 | 1.4 | 0.4 | -0.3 | 0.2 | 0.0 | 0.3 | 0.1 |
| ជប៉ុន | 1.4 | -1.3 | -0.7 | 0.1 | -0.03 | 0.4 | 2.8 | 2.3 | 0.5 | 0.2 | 0.7 | 0.2 |
| សហរដ្ឋអាមេរិក | 3.8 | -0.4 | 1.7 | 3.2 | 2.1 | 1.5 | 1.6 | -0.4 | 0.0 | 0.1 | 0.4 | 1.1 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៦ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4054.2 | 4140.48 | 4187.1 | 4063.6 | 4037.8 | 4027.2 | 4037.6 | 4042.2 | 4056.7 | 4091.8 | 4022.4 | 4056.3 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9699 | 10413.83 | 9089.9 | 8748.0 | 9363.0 | 10419.2 | 11850.2 | 12809.9 | 13125.2 | 13858.0 | 13627.3 | 13324.1 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.52 | 3.2 | 3.1 | 3.1 | 3.1 | 3.3 | 3.6 | 3.7 | 4.1 | 4.2 | 4.0 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.42 | 1.45 | 1.4 | 1.3 | 1.2 | 1.3 | 1.3 | 1.4 | 1.3 | 1.4 | 1.4 | 1.4 |
| ថៃ (បាត) | 33.36 | 34.34 | 31.7 | 30.5 | 31.1 | 30.7 | 32.5 | 32.6 | 33.2 | 35.2 | 35.6 | 35.3 |
| វៀតណាម (ដុង) | 16382 | 17725.24 | 19200.8 | 20574.3 | 20856.9 | 20990.3 | 21138.2 | 21372.9 | 21712.7 | 22164.6 | 22929.4 | 22314.5 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 6.94 | 6.83 | 6.8 | 6.5 | 6.3 | 6.1 | 6.2 | 6.2 | 6.2 | 6.3 | 6.4 | 6.5 |
| ហុងកុង (ដុល្លារហុងកុង) | 7.78 | 7.75 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1137.23 | 1277.76 | 1156.3 | 1108.6 | 1126.6 | 1095.0 | 1053.6 | 1101.7 | 1097.4 | 1170.0 | 1200.8 | 1163.4 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 31.54 | 33.04 | 31.5 | 29.4 | 29.6 | 29.7 | 30.3 | 31.6 | 30.8 | 32.0 | 33.1 | 32.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.84 | 0.72 | 0.8 | 0.7 | 0.8 | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 |
| ជប៉ុន (យ៉េន) | 102.46 | 93.6 | 87.8 | 79.9 | 79.8 | 97.6 | 105.9 | 119.2 | 121.4 | 122.2 | 115.3 | 107.9 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៨-២០១៦ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No.2) - USA (USD/តោន) | 218.2 | 167.3 | 185.9 | 291.7 | 298.4 | 259.4 | 192.9 | 174.2 | 168.4 | 169.5 | 167.1 | 160.0 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (USD/តោន) | 912.2 | 686.8 | 900.8 | 1125.4 | 999.3 | 856.9 | 821.4 | 627.9 | 664.0 | 514.6 | 518.0 | 586.9 |
| កៅស៊ូ SMR 5 USD/តោន) | 2586.3 | 1884.8 | 3405.7 | 4630.6 | 3200.7 | 2575.3 | 1755.6 | 1450.2 | 1525.9 | 1365.5 | 1229.1 | 1190.0 |
| អង្ករ (Thai 100% B) - បាងកក (USD/តោន) | 615.3 | 524.5 | 506.6 | 558.5 | 594.8 | 533.8 | 434.9 | 426.0 | 396.3 | 383.3 | 376.3 | 385.3 |
| សណ្តែកសៀង (US No.1) - USA (USD/តោន) | 460.4 | 414.0 | 449.8 | 540.7 | 591.4 | 538.4 | 491.8 | 363.9 | 393.7 | 347.6 | 358.0 | 328.0 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 95.4 | 60.5 | 76.8 | 106.2 | 109.5 | 105.9 | 96.2 | 50.9 | 60.5 | 48.2 | 38.0 | 31.2 |
| សាំង - US Gulf Coast (សេន/លីត្រ) | 62.2 | 42.9 | 53.3 | 71.9 | 74.6 | 71.2 | 65.6 | 40.1 | 49.0 | 42.2 | 32.9 | 27.9 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 76.2 | 43.1 | 56.1 | 75.7 | 80.7 | 78.4 | 71.5 | 44.6 | 48.4 | 39.9 | 34.0 | 27.2 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី១ ឆ្នាំ២០១៦ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ កើន ៨០,៥% ធៀបនឹងត្រីមាសមុន ដល់ ៩២៣,៧លានដុល្លារ ប៉ុន្តែធ្លាក់ចុះ ៦៧,៩% ធៀបនឹងមួយឆ្នាំមុន។ វិនិយោគក្នុងវិស័យកសិកម្ម កើន ៦,៨% ដល់ ២៧,៦លានដុល្លារ។ អនុមតិវិនិយោគក្នុងអនុវិស័យកាត់ដេរ កើន ២៨,១% ធៀបនឹងត្រីមាសមុនដល់ ៥៥,២លានដុល្លារ។ អនុមតិវិនិយោគសម្រាប់អនុវិស័យសណ្ឋាគារ និងទេសចរណ៍ កើន ១៥០៨% ដល់ ៦១១,១លានដុល្លារ ធៀបនឹង ៣៨,០លានដុល្លារ កាលពីត្រីមាសមុន។

នៅត្រីមាសទី១ នេះដែរ ចំនួនភ្ញៀវបរទេសមកដល់សរុប រួមចុះ ៦,០% ធៀបនឹងត្រីមាសមុន និង ២,២% ធៀបនឹងត្រីមាសទី១ ឆ្នាំមុន។ ភ្ញៀវមកដល់តាមផ្លូវអាកាស កើនឡើង ១៥,២% រីឯភ្ញៀវមកដល់តាមផ្លូវគោក និងផ្លូវទឹក ធ្លាក់ចុះ ២៥,៤% ធៀបនឹងត្រីមាសមុន។

នៅត្រីមាសទី១ ឆ្នាំ២០១៦ ការនាំចេញសរុប កើន ៣,៤% ធៀបនឹងត្រីមាសមុន និង ១០,១% ធៀបនឹងមួយឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ កើន ៤,៧% ដល់ ១៧៥៩,៤លានដុល្លារ ធៀបនឹង ១៦៨១,២លានដុល្លារ កាលពីត្រីមាសមុន។ ការនាំចេញទៅសហរដ្ឋអាមេរិក ធ្លាក់ចុះ ៣,៦% ធៀបនឹងត្រីមាសមុន និង ១៣,៩% ធៀបនឹងឆ្នាំមុន។ ការនាំចេញទៅសហភាពអឺរ៉ុប កើន ៤,៤% ធៀបនឹងត្រីមាសមុន ដល់ ៧៨៩,៦លានដុល្លារ រីឯការនាំចេញទៅបណ្តាប្រទេសអាស៊ាន ធ្លាក់ចុះ ៧,១% មកត្រឹម ២៥,៦លានដុល្លារ។ ការនាំចេញផលិតផលកសិកម្ម រួមចុះ ១៣,៩% ធៀបនឹងត្រីមាសមុន ក្នុងនោះការនាំចេញកៅស៊ូ ធ្លាក់ចុះ ២៤,៥% ឈើ ៦៧,៩% និង អង្ករ ៧,៥%។

នៅត្រីមាសទី១ ដដែលនេះ ការនាំចូល ធ្លាក់ចុះ ៥,៦% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើន ២,៥% ធៀបនឹងឆ្នាំមុន ដល់ ២៧៨៤,៧លានដុល្លារ។ ការនាំចូល សាំងកើន ៤៦,៦% ម៉ាស៊ូតកើន ៨,៨% និងសម្ភារសំណង់កើន ២០,៦% ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី១ ឆ្នាំ២០១៦ ចំណូលរដ្ឋាភិបាលសរុប កើន ២៣,២% ធៀបនឹងត្រីមាសមុន ដល់ ៣៥៣២,៨ប៊ីលានរៀល ក្នុងនោះ ចំណូលចរន្ត កើន ២៤,៧% ដល់ ៣៥១៤,៦ប៊ីលានរៀល។ ចំណូលពន្ធ កើន ៣៥,១% ដល់ ៣២៥៥,៥ប៊ីលានរៀល រីឯចំណូលមិនមែនពន្ធ ធ្លាក់ចុះ ៣៦,៦% មកត្រឹម ២៥៩,១ប៊ីលានរៀល។ នៅត្រីមាសដដែលនេះ ចំណាយសរុប ធ្លាក់ចុះ ៥៣,៨% ធៀបនឹងត្រីមាសមុន មកត្រឹម ២៣៦៧,៩ប៊ីលានរៀល ដោយសារការធ្លាក់ចុះ ៧០,០% (៦២៤,៥ប៊ីលានរៀល) នៃចំណាយមូលធន និង ៤២,៦% (១៧៤៣,៤ប៊ីលានរៀល) នៃចំណាយចរន្ត។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី១ ឆ្នាំ២០១៦ សន្ទស្សន៍ថ្លៃទំនិញសរុប កើន ២,៥%។ ថ្លៃអាហារ និងភេសជ្ជៈមិនមែនស្រា កើន ៤,៧% ប៉ុន្តែថ្លៃដឹកជញ្ជូន ធ្លាក់ចុះ ៦,៥%។ ប្រាក់រៀល ឡើងថ្លៃ ០,៧% ទល់នឹងប្រាក់ដុល្លារ និង ០,២% ទល់នឹងប្រាក់បាតថៃ ប៉ុន្តែធ្លាក់ថ្លៃ ០,៥% ទល់នឹងប្រាក់ដុងវៀតណាម ធៀបនឹងត្រីមាសមុន។ ម៉ាស៊ូតធ្លាក់ថ្លៃ ១៤,៣% ហើយសាំងធ្លាក់ថ្លៃ ៧,៦%។

## ស្ថានភាពក្រីក្រ

នៅខែឧសភា ២០១៦ ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់អ្នករត់ស៊ីក្លូ អ្នកលក់បន្លែតូចតាច អ្នកស៊ីឈ្នួលធ្វើស្រែ អ្នករត់ម៉ូតូឌុប និងកម្មករសំណង់ កើនឡើង បើធៀបនឹងខែដូចគ្នា ឆ្នាំមុន រីឯចំណូលប្រចាំថ្ងៃពិតរបស់អ្នកលីសែង អ្នករើសអេតចាយ អ្នករត់តុភោជនីយដ្ឋាន និងកម្មករកាត់ដេរ ធ្លាក់ចុះ។

ចំណូលរបស់អ្នកស៊ីឈ្នួលធ្វើស្រែ កើន ៤,៨% ធៀបនឹងខែឧសភា ឆ្នាំមុន ដល់ ៧៩១៦រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍ប្រហែល ៤៥% ជាប្រភពចំណូលចម្បងសម្រាប់គ្រួសារខ្លួន ហើយ ៦៧% ប្រាប់ថា គាត់រកចំណូលបានតិចជាងត្រីមាសមុន។ ពលករភាគច្រើនបញ្ជាក់ថា ចំណូលរបស់គាត់ក្នុងខែឧសភា អាចទ្រទ្រង់ជីវភាពគ្រួសារបាន។ ពលករ ៥០% មានជាប់បំណុលគេ ហើយអត្រាការប្រាក់ជាមធ្យមលើការខ្ចីបុលនោះ គឺប្រហែល ៣% ក្នុងមួយខែ។

ប្រាក់កម្រៃប្រចាំថ្ងៃរបស់កម្មករកាត់ដេរ កើន ៦,៣% ដល់ ១៣.៨២៨រៀល។ កម្មករ ៦០% រៀបការរួច។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់ ទទួលបានការអប់រំត្រឹមកម្រិតបឋមសិក្សា។ ជាមធ្យម ពួកគេធ្វើការឲ្យរោងចក្របាន ៤,៥ឆ្នាំហើយ។ ពួកគេភាគច្រើនទទួលបានជំនាញមុនពេលចូលធ្វើការរោងចក្រ តាមរយៈការបណ្តុះបណ្តាលជាលក្ខណៈឯកជន រីឯអ្នកផ្សេងទៀតទទួលបានជំនាញ តាមរយៈការបណ្តុះបណ្តាលក្នុងកន្លែងធ្វើការនៅឯរោងចក្រ។ ជាមធ្យម ពួកគេធ្វើការ ៥៣ម៉ោង/សប្តាហ៍ និងសន្សំប្រាក់បានដល់៦២%នៃប្រាក់កម្រៃរបស់ខ្លួន។ប្រាក់សន្សំភាគច្រើនពួកគេផ្ញើទៅផ្ទះ ហើយវាអាចជួយទ្រទ្រង់ជីវភាពគ្រួសារបាន។ កម្មករ ៤៨% មិនចង់ផ្លាស់ប្តូរការងារទេ ហើយ ៨១% មានសុទិដ្ឋិនិយមថា រោងចក្រគាត់នៅតែមានដំណើរការតទៅអនាគតទៀត។

ចំណូលរបស់អ្នកលក់បន្លែតូចតាច កើន ១១,៥% ធៀបនឹងអង្កេតលើកមុន ដល់ ១៨.៩៧៩រៀល/ថ្ងៃ។អ្នកលក់បន្លែភាគច្រើនជាអ្នកមកពីខេត្តក្រុងផ្សេងទៀត ដូចជា កណ្តាល (៣២,៥%) ស្វាយរៀង (១៥%) ព្រៃវែង (១២,៥%) ភ្នំពេញ (១០%) សៀមរាប (១០%) តាកែវ (១០%) កំពង់ស្ពឺ (៧,៥%) និងកំពង់ចាម (២,៥%)។ ពួកគេ ៧៨% មានដីកសិកម្មពី ១ ទៅ ៣ ហិកតា ហើយអ្នកក្រៅពីនោះ មិនមានដីទេ។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នា ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ ហើយមិនមានមូលធនគ្រប់គ្រាន់សម្រាប់បម្រើអាជីវកម្មរបស់ខ្លួនទេ។

អត្ថបទនេះ រៀបរៀងដោយលោកស្រី ស្រី បុប្ផារ័ត្ន ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

ចំណូលរបស់អ្នករើសអេតចាយ ធ្លាក់ចុះ ៣៤,២% មកត្រឹម ៨៧៣៧រៀល/ថ្ងៃ ដោយសារកំណើនចំនួនអ្នករើសអេតចាយនៅតំបន់ចាក់សម្រាម និងការថយចុះប្រភពសម្រាម។ ពួកគេភាគច្រើន ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ ហើយត្រូវធ្វើការប្រហែល ១០ម៉ោង/ថ្ងៃ ដើម្បីទ្រទ្រង់គ្រួសារខ្លួន។ ជាមធ្យម ពួកគេចាយអស់ ៥៣,៣% នៃចំណូល ហើយភាគច្រើនទៅលើថ្លៃអាហារ (៨៤,២%) ថ្លៃឈ្នួលកន្លែងស្នាក់នៅ (១២,៥%) និងមួយភាគតូចណាស់លើថ្លៃថែទាំសុខភាព និងការចំណាយផ្សេងទៀត។

នៅខែឧសភា ចំនួនកម្មករសំណង់គ្មានជំនាញបានកើនឡើង ប៉ុន្តែសកម្មភាពសាងសង់ក៏កើនឡើងដែរ ដែលនាំឲ្យចំណូលប្រចាំថ្ងៃរបស់ពួកគេ កើនឡើង ៣៩,៧% ដល់ ២០.២២៧រៀល។ អ្នកឆ្លើយសម្ភាសន៍ ៦៥% ធ្វើចំណាកស្រុកមករាជធានីភ្នំពេញ ឬខេត្តសៀមរាប ដើម្បីរកការងារធ្វើ។ ជាមធ្យម ពួកគេធ្វើការ ៨,៥ ម៉ោង/ថ្ងៃ ហើយត្រូវចំណាយប្រាក់ភាគច្រើនទៅលើម្ហូបអាហារ។ ចំណូលរបស់ពួកគេ អាចទ្រទ្រង់គ្រួសារបាន។

ចំណូលរបស់អ្នកលីសែងធ្លាក់ចុះ២០,៣%មកត្រឹម១១.៨៩៨ រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នាធ្វើចំណាកស្រុកមកពីខេត្ត ហើយស្នាក់នៅរួមគ្នាចំនួន ៥នាក់ជាមធ្យមក្នុងមួយបន្ទប់។ ចំណូលរបស់ពួកគេ ចាយវាយជាសំខាន់លើ ម្ហូបអាហារ (៧៦%) ថ្លៃឈ្នួលកន្លែងស្នាក់នៅ (១៧,៥%) ការថែទាំសុខភាព (០,៤%) និងមុខចំណាយផ្សេងទៀត (៦,០%)។ អ្នកឆ្លើយសម្ភាសន៍ ៥៨% ប្រាប់ថា តាំងពីចាប់ផ្តើមធ្វើជាអ្នកលីសែងមក គ្រួសាររបស់ពួកគេមានជីវភាពប្រសើរជាងមុន ប៉ុន្តែមាន ៧,៥% ប្រាប់ថា គ្រួសារខ្លួនមានជីវភាពលំបាកជាងមុន។

ចំណូលប្រចាំថ្ងៃរបស់អ្នករត់តុភោជនីយដ្ឋាន ធ្លាក់ចុះបន្តិចមកត្រឹម ៨១៨៧រៀល។ ពួកគេ ៩៣% ស្នាក់នៅក្នុងហាង។ ពួកគេធ្វើការនេះបាន ៤ឆ្នាំហើយ និងត្រូវបម្រើការក្នុងហាងជាមធ្យម ១១,៨ម៉ោង/ថ្ងៃ។ ពួកគេចំណាយ ២៥,៥% នៃចំណូលសរុបទៅលើម្ហូបអាហារ។ អ្នកឆ្លើយសម្ភាសន៍ ផ្ញើ ៦៩% នៃចំណូលរបស់ខ្លួន ទៅឲ្យគ្រួសារ ហើយប្រាក់ផ្ញើនេះអាចជួយទ្រទ្រង់ជីវភាពគ្រួសារបានតែមួយភាគប៉ុណ្ណោះ។

តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៨-១៦*

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 92.0 | 615.0 | 530.7 | 725.0 | 531.6 | 930.5 | 56.5 | 25.8 | 38.1 | 79.1 | 26.8 | 27.6 |
| ឧស្សាហកម្ម | 724.9 | 818.5 | 403.7 | 2860.1 | 829.3 | 3257.0 | 1002.5 | 342.8 | 130.9 | 130.6 | 410.4 | 252.4 |
| *កាត់ដេរ* | 142.8 | 90.1 | 122.8 | 393.9 | 497.0 | 324.1 | 393.5 | 63.9 | 42.4 | 63.7 | 55.2 | 70.8 |
| សេវាកម្ម | 10,003.2 | 4432.0 | 1337.3 | 3425.4 | 916.6 | 140.7 | 622.6 | 2504.6 | 85.6 | 69.7 | 74.5 | 643.6 |
| *សណ្ឋាគារ និងទេសចរណ៍* | 8758.1 | 3980.1 | 1105.1 | 2850.9 | 691.5 | 106.0 | 446.9 | 60.6 | 0.0 | 0.0 | 38.0 | 611.1 |
| សរុប | 10,570.9 | 5865.5 | 2271.7 | 7010.4 | 2278.0 | 4328.0 | 1583.9 | 2873.2 | 254.6 | 279.4 | 511.7 | 923.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | | 1816.8 | -91.1 | 9.7 | 83.1 | 80.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 308.6 | -45.5 | -61.3 | 209.0 | -67.5 | 90.1 | 63.4 | 573.0 | -33.2 | -55.3 | 241.4 | -67.9 |

*Including expansion project approvals. Source: Cambodian Investment Board

តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | 187.8 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៨-១៦

| | | | | | | | | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | Q1 | Q2 | Q3 | Q4 | Q1 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1239.4 | 1111.7 | 1304.3 | 1480.4 | 1722.1 | 2017.7 | 2273.5 | 725.1 | 497.4 | 563.8 | 681.3 | 785.0 |
| តាមផ្លូវគោក និងទឹក | 881.9 | 999.7 | 1094.6 | 1401.4 | 1862.2 | 2192.5 | 2229.3 | 647.6 | 496.7 | 481.1 | 747.0 | 557.4 |
| សរុប | 2121.3 | 2111.5 | 2398.9 | 2881.8 | 3584.3 | 4210.2 | 4502.8 | 1372.6 | 994.2 | 1044.9 | 1428.4 | 1342.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | | 5.4 | -27.6 | 5.1 | 36.7 | -0.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 5.5 | -0.5 | 13.6 | 20.1 | 24.4 | 17.5 | 7.0 | 8.3 | 6.5 | 4.6 | 9.6 | -2.4 |

Source: Ministry of Tourism

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៨-១៦ *

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 3097.8 | 2901.6 | 3630.2 | 4929.5 | 6106.4 | 6982.4 | 8106.0 | 2170.1 | 2182.0 | 2595.0 | 2309.3 | 2388.3 |
| ក្នុងនេះ៖ សម្លៀកបំពាក់ទៅ | 2986.2 | 2565.3 | 3223.4 | 4259.6 | 5015.4 | 5386.1 | 5960.5 | 1548.8 | 1601.7 | 1995.3 | 1681.2 | 1759.4 |
| - *សហរដ្ឋអាមេរិក* | 1908.3 | 1512.6 | 1853.9 | 2055.3 | 2143.3 | 2075.2 | 1963.6 | 491.1 | 494.3 | 585.3 | 438.8 | 423.1 |
| - *សហភាពអឺរ៉ុប* | 689.0 | 644.7 | 809.5 | 1322.2 | 1716.9 | 1969.6 | 2403.7 | 617.3 | 685.9 | 844.1 | 756.6 | 789.6 |
| - *អាស៊ាន* | 10.8 | 6.9 | 9.9 | 17.6 | 39.4 | 60.2 | 83.3 | 24.8 | 24.6 | 26.4 | 27.5 | 25.6 |
| - *ជប៉ុន* | 25.2 | 44.6 | 86.5 | 147.0 | 188.6 | 278.7 | 383.1 | 121.4 | 93.6 | 170.8 | 138.4 | 176.0 |
| - *ប្រទេសផ្សេងៗ* | 352.9 | 356.5 | 463.6 | 717.5 | 927.2 | 1002.9 | 1126.8 | 294.2 | 303.4 | 368.8 | 319.9 | 345.2 |
| កសិកម្ម | 44.5 | 73.1 | 164.9 | 362.1 | 376.7 | 554.5 | 624.4 | 150.3 | 127.3 | 111.4 | 159.7 | 137.5 |
| - *កៅស៊ូ* | 35.8 | 51.6 | 89.1 | 197.6 | 176.6 | 175.2 | 153.9 | 41.7 | 40.9 | 42.1 | 40.7 | 30.7 |
| - *ឈើ* | 3.4 | 3.5 | 34.1 | 48.8 | 36.8 | 73.6 | 132.0 | 13.9 | 9.8 | 7.3 | 15.3 | 4.9 |
| - *ត្រី* | 2.3 | 4.0 | 2.8 | 3.1 | 2.0 | 1.2 | 0.8 | 0.2 | 0.2 | 0.1 | 0.1 | 0.2 |
| - *អង្ករ* | 2.6 | 10.9 | 34.7 | 106.6 | 146.4 | 262.3 | 248.5 | 89.5 | 72.4 | 54.7 | 98.8 | 91.4 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 0.5 | 3.0 | 4.1 | 6.0 | 14.9 | 42.4 | 89.1 | 5.2 | 4.0 | 7.2 | 4.9 | 10.3 |
| ផ្សេងៗ | 67.1 | 263.2 | 242.0 | 307.9 | 714.4 | 1088.2 | 1520.1 | 471.0 | 452.9 | 488.0 | 468.4 | 491.3 |
| ការនាំចូលសរុប ក្នុងនេះ៖ | 4272.0 | 4332.0 | 5190.6 | 6375.9 | 8593.3 | 8639.4 | 10,295.4 | 2717.3 | 2920.3 | 2907.9 | 2949.1 | 2784.7 |
| សាំង | 84.9 | 91.1 | 108.6 | 294.4 | 308.0 | 306.4 | 334.7 | 34.5 | 92.2 | 96.5 | 65.1 | 95.4 |
| ម៉ាស៊ីត | 119.5 | 180.7 | 203.8 | 447.0 | 559.5 | 569.1 | 602.3 | 45.1 | 152.7 | 139.6 | 150.0 | 163.1 |
| សម្ភារសំណង់ | 56.3 | 49.7 | 57.6 | 48.1 | 66.1 | 80.8 | 117.6 | 12.4 | 42.0 | 45.9 | 42.1 | 50.8 |
| ផ្សេងៗ | 4011.8 | 4010.0 | 4820.6 | 5586.4 | 7659.1 | 7682.6 | 9240.7 | 835.2 | 2633.0 | 2626.0 | 2691.9 | 2475.0 |
| ជញ្ជីងពាណិជ្ជកម្ម | -1174.7 | -1429.9 | -1560.5 | -1446.4 | -1341.6 | -1610.9 | -2184.3 | -547.2 | -738.3 | -312.9 | -639.7 | -396.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | - | 3.8 | 3.4 | 24.6 | -15.7 | 4.7 |
| ការនាំចេញសរុប | - | - | - | - | - | - | - | 1.5 | 0.5 | 18.9 | -11.0 | 3.4 |
| ការនាំចូលសរុប | - | - | - | - | - | - | - | -3.2 | 7.5 | -0.4 | 1.4 | -5.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 1.6 | -14.1 | 25.7 | 32.1 | 17.7 | 7.4 | 10.7 | 5.8 | 16.1 | 22.8 | 12.6 | 13.6 |
| ការនាំចេញសរុប | 1.6 | -6.3 | 25.1 | 35.8 | 23.9 | 14.3 | 16.1 | 9.8 | 17.3 | 21.7 | 8.1 | 10.1 |
| ការនាំចូលសរុប | 13.3 | 1.4 | 19.8 | 22.8 | 16.8 | 15.4 | 19.7 | 21.4 | 19.2 | 4.0 | 5.0 | 2.5 |

* Import data include tax-exempt imports. Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (website)

### តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៨-១៦ (ប៊ីលានរៀល)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ចំណូលសរុប | 5290.0 | 5989.0 | 5989.0 | 6251.4 | 7691.9 | 8255.2 | 10,543.4 | 2647.8 | 3301.6 | 3063.8 | 2867.3 | 3532.8 |
| ចំណូលចរន្ត | 5210.7 | 5859.1 | 5859.1 | 6179.3 | 7443.8 | 8233.2 | 10,359.4 | 2638.0 | 3274.5 | 3028.7 | 2818.2 | 3514.6 |
| ចំណូលពន្ធ | 4409.9 | 4693.0 | 4693.0 | 5277.5 | 6334.8 | 7198.1 | 8995.2 | 2430.6 | 3006.1 | 2656.2 | 2409.7 | 3255.5 |
| ពន្ធក្នុងស្រុក | 3248.4 | 3533.6 | 3533.6 | 4071.6 | 5002.8 | 5728.1 | 7226.5 | 2012.6 | 2481.6 | 2153.9 | 1943.6 | 2715.4 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1161.5 | 1159.4 | 1159.4 | 1205.9 | 1331.7 | 1470.0 | 1822.7 | 418.0 | 524.5 | 502.3 | 466.1 | 540.1 |
| ចំណូលមិនមែនពន្ធ | 800.8 | 1166.1 | 1166.1 | 901.8 | 1118.2 | 1035.2 | 1310.3 | 207.4 | 268.5 | 372.5 | 408.5 | 259.1 |
| ចំណូលលើទ្រព្យសម្បត្តិ | 78.0 | 291.1 | 291.1 | 63.8 | 143.0 | 84.0 | 88.5 | 3.0 | 16.7 | 35.9 | 21.7 | 8.2 |
| លក់ទំនិញ និងសេវា | 424.7 | 460.1 | 460.1 | 588.7 | 667.4 | 750.3 | 871.2 | 189.6 | 219.2 | 304.6 | 333.9 | 198.3 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 298.2 | 408.9 | 408.9 | 249.3 | 298.8 | 200.8 | 350.5 | 14.8 | 32.6 | 31.8 | 53.0 | 52.7 |
| ចំណូលជាមូលធន | 79.3 | 129.9 | 129.9 | 72.1 | 247.9 | 73.4 | 184.0 | 9.8 | 27.1 | 35.0 | 49.1 | 18.3 |
| ចំណាយសរុប | 6297.8 | 8784.7 | 8784.6 | 9032.4 | 9660.9 | 12,535.7 | 13,306.5 | 2093.3 | 1964.8 | 3337.5 | 5121.3 | 2367.9 |
| ចំណាយជាមូលធន | 2574.4 | 2853.2 | 2853.2 | 3546.9 | 3628.3 | 5567.5 | 5590.7 | 654.4 | 584.7 | 649.9 | 2083.4 | 624.5 |
| ចំណាយចរន្ត | 3809.0 | 4773.1 | 4773.1 | 5341.2 | 6188.4 | 6968.3 | 7715.8 | 1438.9 | 1380.1 | 2687.7 | 3038.0 | 1743.4 |
| បៀវត្សរ៍ | 1397.0 | 2048.8 | 2048.8 | 2170.6 | 2486.6 | 2997.3 | 3755.5 | 945.3 | 959.1 | 1281.2 | 1086.3 | 1133.1 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 927.1 | 1099.4 | 1099.4 | 1518.8 | 1586.8 | 1563.0 | 1627.0 | 194.3 | 207.1 | 544.0 | 797.1 | 259.1 |
| ចំណាយចរន្តផ្សេងទៀត | 1384.9 | 1624.8 | 1624.8 | 1651.8 | 2115.1 | 2408.0 | 2333.4 | 299.3 | 213.9 | 862.4 | 1154.6 | 351.2 |
| សមតុល្យជាទូទៅ | -1007.8 | -2795.7 | -2795.7 | -1271.4 | -1969.0 | -4280.6 | -2763.1 | 554.5 | 1336.8 | -273.8 | -2254.0 | 1164.9 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 2055.1 | 1845.2 | 1845.2 | -2781.0 | 2457.8 | 4326.2 | 3972.1 | 368.9 | 330.1 | 297.6 | 1414.8 | 270.0 |
| ហិរញ្ញប្បទានក្នុងស្រុក | -127.0 | 938.6 | 938.6 | 2379.2 | -332.9 | 824.4 | -1428.7 | -2464.8 | -793.3 | -259.1 | -109.4 | -1471.3 |

Source: MEF website

### តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៨-១៦

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| (ឆ្នាំគោល ២០០៦) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 4.7 | 5.8 | 4.1 | 5.4 | 2.3 | 3.0 | 3.9 | 1.0 | 1.0 | 0.8 | 2.0 | 2.5 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 6.4 | 9.9 | 4.4 | 6.5 | 2.5 | 3.9 | 4.9 | 4.2 | 3.9 | 3.3 | 4.7 | 4.7 |
| - ដឹកជញ្ជូន | 9.1 | 5.8 | 7.0 | 6.9 | 3.3 | -0.6 | -1.0 | -10.9 | -7.9 | -9.1 | -8.9 | -6.5 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4119.0 | 4062.7 | 4187.1 | 4063.6 | 4039.2 | 4036.2 | 4060.4 | 4042.2 | 4056.7 | 4091.8 | 4050.9 | 4022.4 |
| រៀលក្នុង ១ បាតថៃ | 108.7 | 122.8 | 133.1 | 133.2 | 130.0 | 124.9 | 119.4 | 124.4 | 122.6 | 116.8 | 113.6 | 113.4 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.1 | 25.0 | 21.7 | 19.7 | 19.4 | 19.1 | 18.7 | 19.0 | 18.8 | 18.6 | 18.2 | 18.1 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 70.6 | 83.2 | 147.5 | 184.5 | 200.9 | 175.9 | 152.3 | 150.9 | 144.4 | 136.0 | 130.9 | |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3140.0 | 3262.3 | 3859.3 | 4761.2 | 4941.2 | 4852.1 | 4934.1 | 3823.4 | 4032.0 | 3840.2 | 3389.4 | 2903.8 |
| ថ្លៃសាំង (រៀល/លីត្រ) | 4004.0 | 4005.0 | 4368.1 | 5044.5 | 5312.7 | 5083.3 | 5155.7 | 3986.2 | 4189.0 | 4048.9 | 3582.5 | 3310.6 |

Sources: NIS, NBC and CDRI

### តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៨-១៦ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 10,345.6 | 14,655.0 | 16,697.9 | 17,893.9 | 18,154.5 | 21,260.1 | 26,699.7 | 26,823.0 | 27,975.3 | 26,359.2 | 26,665.5 | 29,247.8 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 1513.3 | 1573.0 | 2778.9 | 5760.8 | 10,437.4 | 11,508.3 | 15,859.8 | 16,863.2 | 18,178.3 | 20,600.9 | 22,157.6 | 21,643.0 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2987.0 | -2252.0 | -2126.6 | -2123.1 | -2486.4 | -2794.9 | -4359.1 | -5064 | -5666.1 | -5933.1 | -6428.8 | -7621.2 |
| ឥណទានដល់វិស័យឯកជន | 9894.1 | 10,532.0 | 13,331.2 | 17,552.8 | 23,536.6 | 27,608.8 | 36,244.6 | 37,759.4 | 40,995.0 | 43,807.1 | 46,071.0 | 47,627.0 |
| រូបិយវត្ថុទូទៅ M2 | 11,858.9 | 16,228.0 | 19,476.8 | 23,654.7 | 28,591.9 | 32,768.4 | 42,559.5 | 43,685.2 | 46,153.7 | 46,960.1 | 48,823.1 | 50,890.9 |
| រូបិយវត្ថុ M1 | 2399.6 | 3120.0 | 3220.9 | 3956.2 | 4045.7 | 4878.2 | 6308.4 | 6628.0 | 6293.1 | 6287.5 | 6741.4 | 6717.8 |
| រូបិយវត្ថុផ្សេងៗ | | | | | | | | 37,058.2 | 39,860.6 | 40,672.6 | 42,081.7 | 44,173.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 4.8 | 36.9 | 20.0 | 17.8 | 20.9 | 14.6 | 29.9 | 24.2 | 20.6 | 15.2 | 14.7 | 16.5 |
| រូបិយវត្ថុ M1 | 16.9 | 30.1 | 3.2 | 16.9 | 2.3 | 20.6 | 29.3 | 23.3 | 20.3 | 12.6 | 6.9 | 1.4 |
| រូបិយវត្ថុផ្សេងៗ | 2.2 | 38.6 | 24.0 | 17.9 | 44.6 | 13.6 | 30.0 | 24.4 | 20.7 | 15.6 | 16.1 | 19.2 |

Source: National Bank of Cambodia

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2010 | 2011 | 2012 | 2013 | 2014 | 2015** | | 2016 | | 2015** | 2016 | |
| | | | | | | កុម្ភៈ | ឧសភា | កុម្ភៈ | ឧសភា | | កុម្ភៈ | ឧសភា |
| អ្នករត់ស៊ីក្លូ | 9055 | 9532 | 10,303 | 10,438 | 10,774 | 12,408 | 11,677 | 11,880 | 11,898 | 15.1 | -4.3 | 1.9 |
| អ្នកលីសែង | 9964 | 10,785 | 12,143 | 13,247 | 13,580 | 16,094 | 14,782 | 14,888 | 11,774 | 15.1 | -7.5 | -20.3 |
| អ្នកលក់បន្លែតូចតាច | 8266 | 8337 | 10,771 | 11,366 | 14,751 | 14,379 | 17,020 | 20,337 | 18,979 | 7.6 | 41.4 | 11.5 |
| អ្នករើសអេតចាយ | 6698 | 8388 | 8680 | 9819 | 9173 | 10,181 | 13,272 | 11,159 | 8737 | 34.6 | 9.6 | -34.2 |
| អ្នករត់តុភោជនីយដ្ឋាន* | 5607 | 5986 | 6111 | 6697 | 7789 | 8111 | 8188 | 7860 | 8187 | 6.9 | -3.1 | -0.01 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5691 | 5695 | 6151 | 6599 | 7514 | 7955 | 7552 | 8,484 | 7916 | 0.1 | 6.6 | 4.8 |
| កម្មកររោងចក្រកាត់ដេរ | 7746 | 8409 | 8932 | 10,161 | 11,178 | 14,644 | 14,803 | 14,937 | 13,828 | 8 | 2.0 | -6.3 |
| អ្នករត់ម៉ូតូឌុប | 10,623 | 11,568 | 12,930 | 13,450 | 13,386 | 13,939 | 13,761 | 15,526 | 15,425 | 8.3 | 11.4 | 12.1 |
| កម្មករសំណង់គ្មានជំនាញ | 8790 | 10,307 | 11,078 | 13,184 | 13,336 | 15,981 | 14,474 | 16,164 | 20,227 | 16.4 | 1.1 | 39.7 |
| កម្មករសំណង់មានជំនាញ | 11,952 | 13,159 | 13,743 | 15,442 | 17,420 | 16,336 | 18,656 | 18,853 | 21,150 | 34.1 | 15.4 | 13.4 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. **Data in November 2015 is not available.
Source: CDRI

*តពីទំព័រ ២៤* **ព័ត៌មានថ្មីៗ...**

**ថ្ងៃទី១៤ មិថុនា៖** លោកនាយកប្រតិបត្តិ បានចូលរួមក្នុងសិក្ខាសាលាសភាស្តីពី "ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងថវិកាជាតិឆ្នាំ២០១៧" រៀបចំឡើងដោយ រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា។ សិក្ខាសាលានេះ ជាឱកាសដ៏វិសេសសម្រាប់ធ្វើទំនាក់ទំនងជាមួយ អ្នកកសាងគោលនយោបាយជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាល និងសភាជាតិ និងដៃគូអភិវឌ្ឍន៍អន្តរជាតិផ្សេងៗ។

**ថ្ងៃទី២៧-២៩ មិថុនា៖** ក្រុមស្រាវជ្រាវផ្នែកអប់រំ និងលោកនាយកប្រតិបត្តិ បានធ្វើទស្សកិច្ចនៅកំពង់ផែស្វយ័តនិងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ វិទ្យាស្ថានបច្ចេកវិទ្យាគិរីរម្យ និងវិទ្យាស្ថានពហុបច្ចេកទេសជាតិកម្ពុជា ក្នុងគោលបំណងបង្កើតទំនាក់ទំនងការងារនាពេលអនាគត សម្រាប់កិច្ចសហការស្រាវជ្រាវពីតម្រូវការធនធានមនុស្ស និងសមត្ថភាពឡូជីស្ទិក ដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា។

## ការស្រាវជ្រាវ

### ផ្នែកកសិកម្ម

ផ្នែកនេះកំពុងអនុវត្តគម្រោងស្រាវជ្រាវចំនួន ៧។ ការសិក្សាស្តីពី *សកម្មភាពបង្កើតប្រាក់ចំណូលមិនមែនកសិកម្មនៅកម្ពុជា* ដែលទទួលមូលនិធិពី អង្គការកសិកម្ម និងស្បៀងអាហារ (FAO) បានចប់សព្វគ្រប់ ហើយរបាយការណ៍សម្រេច និងសង្ខេបគោលនយោបាយ បានបញ្ជូនទៅម្ចាស់ជំនួយរួចរាល់។ របាយការណ៍សម្រេចសម្រាប់ គម្រោង *ផលប៉ះពាល់នៃចំណាយសាធារណៈផ្នែកអប់រំទៅលើមូលធនមនុស្ស ភាពក្រីក្រ និងវិសមភាព៖ វិធីសាស្ត្រ CGE សម្រាប់កម្ពុជា* ដែលទទួលបានជំនួយទ្រទ្រង់ពី អង្គការភាពជាដៃគូសម្រាប់គោលនយោបាយសេដ្ឋកិច្ច (PEP) ក៏បានបញ្ជូនទៅម្ចាស់ជំនួយហើយដែរ។ ការវិភាគទិន្នន័យបានចប់សព្វគ្រប់ សម្រាប់គម្រោង *ផលប៉ះពាល់នៃគោលនយោបាយជំរុញការនាំចេញអង្ករ និងសន្តិសុខស្បៀង* ហើយបច្ចុប្បន្នក្រុមស្រាវជ្រាវកំពុងសិក្សាលើឯកសារពាក់ព័ន្ធ និងចងក្រងរបាយការណ៍។ នៅខែមិថុនា ក្រុមស្រាវជ្រាវបានរៀបចំសិក្ខាសាលាសម្រាប់អ្នកពាក់ព័ន្ធ ដើម្បីបង្ហាញលទ្ធផលស្រាវជ្រាវនៃគម្រោង *កសិកម្មមានការស្រោចស្រពនៅកម្ពុជា* ដែលទទួលបានជំនួយទ្រទ្រង់ពី សាកលវិទ្យាល័យជាតិអូស្ត្រាលី។ អង្កេតគោលសម្រាប់គម្រោង *ការសាកល្បងគំរូបែបថ្មីនៃការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម នៅក្នុងគម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច (PADEE) របស់កម្ពុជា* ដែលទទួលមូលនិធិពី វិទ្យាស្ថានស្រាវជ្រាវពីគោលនយោបាយស្បៀងអាហារអន្តរជាតិ (IFPRI) បានអនុវត្តចប់សព្វគ្រប់ ហើយទិន្នន័យស្រេចបាច់បានបញ្ជូនទៅឲ្យ IFPRI រួចរាល់។ គម្រោង *ការវិភាគពីគោលនយោបាយស្រូវ* ដែលទទួលបានមូលនិធិពី គំនិតផ្តួចផ្តើមផ្នែកគោលនយោបាយសាធារណៈ សម្រាប់តំបន់មេគង្គក្រោម (LMPPI) បានចាប់អនុវត្តទៅមុខ។ គម្រោងស្តីពី *ការវាយតម្លៃចុងក្រោយលើផលប៉ះពាល់នៃកម្មវិធី HARVEST* ដែលទទួលជំនួយហិរញ្ញវត្ថុពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ក៏កំពុងដំណើរការទៅមុខដែរ។